# អង្គការកម្ពុជា-ហូឡង់

# របាយការណ៍ប្រចាំឆ្នាំ២០១៦

## ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៦

## I- ប្រវត្តិសង្ខេបរបស់អង្គការកម្ពុជា-ហូឡង់ Background

**អង្គការកម្ពុជា-ហូឡង់** គឺជាអង្គការមនុស្សធម៌មិនមែនរដ្ឋាភិបាលមិនស្វែងរកប្រាក់កម្រៃ អព្យាក្រិតមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា និងមិនប្រកាន់និន្នាការនយោបាយ ដែលបានធ្វើសកម្មភាពតាំងពីឆ្នាំ ២០០៨ និងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃលេខ ២១៣៥ សជណ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ ដើម្បីបំពេញការងារផ្នែកបង្រៀនភាសាអង់គ្លេសដោយឥតគិតថ្លៃ។

អង្គការកម្ពុជា-ហូឡង់មានសកម្មភាពចំបងបំផុតគឺ ផ្តល់ការសិក្សាភាសាអង់គ្លេសដោយមិនយកកម្រៃដល់កុមារនិង យុវជនកម្ពុជា ជាពិសេសគ្រួសារដែលគ្មានលទ្ធភាពចំណាយសំរាប់ការសិក្សារបស់កូននៅតាមស្រុកស្រែកទីជនបទក្នុងឃុំខ្នារពោធិ៍ ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ជាបន្តបន្ទាប់អង្គការកម្ពុជា-ហូឡង់បានពង្រីកសកម្មភាពរបស់ខ្លួនលើ កម្មវិធីទឹកស្អាត ការគាំទ្រផ្នែកសង្គម ការគាំទ្រផ្នែកសុខភាពរហូតដល់បច្ចុប្បន្ន។

## II- គម្រោងគាំទ្រនិងសមិទ្ធិផលសំរេចបាន Achievement of Program

### ១ - គម្រោងគាំទ្របង្រៀនភាសាអង់គ្លេស

ការបង្រៀនភាសាអង់គ្លេសធ្វើឡើងមាន គោលបំណងដើម្បីផ្តល់ឱកាសដល់កុមារាកុមារីជាពិសេសប្អូនៗសិស្សានុសិស្សនៅតាមទីជនបទដាច់ស្រយ៉ាលបានទទួលការបង្រៀនភាសាអង់គ្លេសដូចជាអ្នកដែលរស់នៅក្នុងទីក្រុងផងដែរ។ ការបង្រៀនភាសាអង់គ្លេសរៀបចំនៅម៉ោងព្រឹក ម៉ោងរសៀល និងម៉ោងល្ងាចទៅតាមតំរូវការរបស់សហគមន៍ មិនតែប៉ុណ្ណោះអង្គការបានទទួលអ្នកស្ម័គ្រចិត្តបរទេសនានាៗមកជួយបង្រៀនជាមួយគ្រូក្នុងស្រុកផងដែរ។ និងមានសំភារៈសិក្សាសំរាប់ផ្គត់ផ្គង់ជូនដល់សិស្សដោយឥតគិតថ្លៃ និងការបង្រៀនប្រើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល៕

**ចំនួនថ្នាក់រៀន និងសិស្សបានចូលរៀន;**

| ល.រ | កំរិតនៃការសិក្សា/ថ្នាក់ | សមិទ្ធិផលសំរេចបាន Achievement | |
|---|---|---|---|
| | | ចំនួនថ្នាក់ | ចំនួនសិស្ស |
| ១ | Funny Class | 1 | 25 |
| ២ | Start Class | 4 | 114 |

| | | | |
|---|---|---|---|
| ៣ | Let’s Go I | 2 | 50 |
| ៤ | Let’s Go II | 2 | 67 |
| ៥ | Let’s Go III | 1 | 35 |
| ៦ | Let’s Go IV | 0 | 0 |
| ៧ | Let’s Go V | 0 | 0 |
| ៨ | Let’s Go VI | 2 | 29 |
| | **Total** | **13** | **320/ 178** |

## ២ - **គម្រោងគាំទ្រផ្នែកសុខភាព** Health Program

តាមការស្នើសុំពីប្រជាពលរដ្ឋ ជាពិសេសអាជ្ញធរឃុំខ្នារពោធិ៍ អង្គការកម្ពុជាហូឡង់បានផ្តល់មូលនិធិសាងសង់ ប៉ុស្តិ៍សុខភាពខ្នារពោធិ៍ ស្ថិតនៅក្នុងឃុំខ្នារពោធិ៍ ស្រុកសូទ្រនិគម និងបានដាក់អោយប្រើប្រាស់នៅថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១០។ ប៉ុស្តិ៍សុខភាពខ្នារពោធិ៍មានបុគ្គលិកចំនួន៩នាក់រួមទាំងអ្នកសំអាត ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពចាន់សក្នុងស្រុកប្រតិបត្តិសូទ្រនិគម។ ដើម្បីគាំទ្រសកម្មភាព សេវាសុខភាពជូនប្រជាពលរដ្ឋនៅមូលដ្ឋានដាច់ស្រយ៉ាល អង្គការកម្ពុជា ហូឡង់បានគាំទ្រជួយបំពេញបន្ថែមទាំង ផ្នែកថវិកាដូចជាប្រាក់ខែដល់បុគ្គលិកចំនួន៦នាក់និងសំភារះរួមទាំងថ្នាំពេទ្យសំរាប់ដំណើរការផ្តល់សេវាជូនប្រជាពលរដ្ឋផងដែរ។

### ចំនួនអ្នកជំងឺដែលបានមកប្រើប្រាស់សេវាសុខភាពនៅមណ្ឌលសុខភាពខ្នារពោធិ៍

| ពណ៌នា Description | **លទ្ធផល** Achievement 2016 | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | **Jan** | **Feb** | **Mar** | **Apr** | **May** | **Jun** | **Jul** | **Aug** | **Sep** | **Oct** | **Nov** | **Dec** | **Total** |
| ការពិនិត្យជំងឺក្រៅ OPD | **1224** | **1183** | **1185** | **924** | **939** | **945** | **1244** | **1306** | **950** | **1320** | **966** | **875** | **13061** |
| ការពន្យាកំណើ Birth spacing | 94 | 64 | 73 | 60 | 77 | 58 | 76 | 73 | 71 | 68 | 81 | 82 | **877** |
| ពិនិត្យផ្ទៃពោះ ANC | 75 | 52 | 60 | 43 | 51 | 54 | 50 | 50 | 40 | 59 | 58 | 61 | 653 |
| ការសំរាលកូន (Delivery) | 16 | 4 | 8 | 15 | 8 | 6 | 6 | 5 | 3 | 5 | 6 | 5 | **87** |
| ព្យាបាលធ្មេញ Dental Care | 0 | 0 | 0 | 0 | 0 | 7 | 6 | 3 | 7 | 8 | 6 | 0 | **37** |
| ព្យាបាលភ្នែក (Eye Care) | 0 | 0 | 9 | 17 | 9 | 20 | 10 | 17 | 20 | 9 | 7 | 0 | **118** |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្តល់វីតាមីន (Vittamin A) | 0 | 0 | 0 | 0 | 682 | 0 | 0 | 0 | 0 | 0 | 659 | 0 | **1341** |
| ផ្តល់វ៉ាក់សាំង (Vacination) | 344 | 195 | 206 | 185 | 273 | 282 | 280 | 262 | 251 | 513 | 257 | 250 | **3298** |
| ការបញ្ជូនអ្នកជម្ងឺ | 0 | 0 | 0 | 1 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | **3** |
| **សរុប Total** | **1746** | **1798** | **1541** | **1245** | **2039** | **1374** | **1672** | **1716** | **1342** | **1982** | **2040** | **1273** | **19475** |

**ផ្សេងៗ:**

- ធ្វើរបងខាងមុខមណ្ឌលសុខភាព
- ដឹកនាំគ្រូពេទ្យស្ម័គ្រចិត្តបរទេសមកធ្វើការមនុស្សធម៌នៅមណ្ឌលសុខភាពចំនួន៨នាក់
- ផ្គត់ផ្គង់ថ្នាំពេទ្យនឹងសម្ភារៈសំរាប់មណ្ឌលសុខភាព
- ផ្តល់ជូនវ៉ែនតាមីញូមនិងការពារពន្លឺថ្ងៃចំនួន ១០០គូរ
- លាបថ្នាំជញ្ជាំងអាគារមណ្ឌលសុខភាពខាងមុខមួយបន្ទប់
- ជួសជុលរឺម៉កកង់បីសំរាប់ដឹកនឹងបញ្ជូនអ្នកជំងឺចំនួនមួយគ្រឿង
- ឧបត្ថមប្រាក់បៀវត្សបន្ថែមប្រចាំខែដល់បុគ្គលិកចំនួន៦នាក់

## ៣ - គម្រោងគាំទ្រផ្នែកសង្គម

ដើម្បីចូលរួមលើកកម្ពស់ជីវភាពរបស់ប្រជាជនទីទល់ក្រនៅតាមជនបទ អង្គការកម្ពុជា-ហូឡង់បានសហការ ជាមួយអាជ្ញាឃុំ និងភូមិ ធ្វើការកំណត់អត្តសញ្ញាណក្រីក្រដើម្បីផ្តល់ការផ្គត់ផ្គង់ដូចជា; សាងសង់ផ្ទះថ្មី ជួសជុលផ្ទះ ផ្គត់ផ្គង់សំលៀកបំពាក់ ផ្គត់ផ្គង់អាហារក្មេងៗ ផ្គត់ផ្គង់បង្គន់អនាម័យ ផ្តល់កង់ នៅតំបន់គោលដៅរបស់គម្រោងនៃ អង្គការកម្ពុជា-ហូឡង់។

ខាងក្រោមជាចំនួនលទ្ធផល;

| ល.រ | ការពិពណ៌នា | សមិទ្ធិផលសំរេចបាន Achievement |
|---|---|---|
| ១ | សាងសង់ផ្ទះថ្មីជូនគ្រួសារក្រីក្រ<br>Built new house for poor family | 2 Houses |
| ២ | ផ្គត់ផ្គង់កង់ថ្មីជូនគ្រួសារក្រីក្រ<br>Supported the new bikes for poor family | 2 bikes |
| ៣ | ផ្គត់ផ្គង់សំលៀកបំពាក់ដល់ជនក្រីក្រនិងកុមារកំព្រា<br>Supported clothes for poor people and poor kids | 50 sets |
| | ផ្គត់ផ្គង់ធុងបាញ់ថ្នាំដំណាំជូនគ្រួសារក្រីក្រ<br>Supported praying bucket the vegetable | 1 family |

| | | |
|---|---|---|
| ៤ | ផ្គត់ផ្គង់ម្ហូបអាហារដល់គ្រួសារក្រីក្រ<br>Supported meals for poor people | 2 families |
| ៥ | ផ្គត់ផ្គង់ម្ហូបអាហារ សំលៀកបំពាក់និងកន្លែងស្នាក់នៅដល់ក្មេងកំព្រាអំឡុងពេលសិក្សា<br>Supported meals for poor kids | 10 kids |

## ៤ - គម្រោងគាំទ្រផ្នែកអនាម័យទឹកស្អាត

ស្ថិតនៅក្រោមគម្រោងសកម្មភាពរបស់ខ្លួនអង្គការកម្ពុជា-ហូឡង់បានរួមចំណែកផ្គត់ផ្គង់និង សាងសង់អណ្តូងថ្មី ដើម្បីចូលរួមលើកកម្ពស់អនាម័យទឹកស្អាតជូនដល់ប្រជាជនទីទាល់ក្រនៅតាមទីជនបទនោះ។

| ល.រ | ការពិពណ៌នា | សមិទ្ធិផលសំរេចបាន<br>Achievement |
|---|---|---|
| ១ | សាងសង់អណ្តូងស្នប់ថ្មីដល់គ្រួសារទីទាល់ក្រ<br>Built new water pumps for poor family | ១ អណ្តូង |
| ២ | ជួសជុលអណ្តូងស្នប់ចាស់ដល់គ្រួសារទីទាល់ក្រ<br>Repaired water pump for poor family | 0 អណ្តូង |
| ៣ | សាងផ្តល់ជូនធុងចំរោះទឹកស្អាតដល់គ្រួសារទីទាល់ក្រ Supported water filter for poor family | 0 ធុងចំរោះ |
| ៤ | ជីកស្រះជូនប្រជាជនក្នុងឃុំគោលដៅគម្រោង<br>Dug pond for people in community | 0 |
| ៥ | ផ្គត់ផ្គង់បង្គន់អនាម័យដល់គ្រួសារក្រីក្រ<br>Supported toilet for poor family | 0 បង្គន់ |

## ៥ - គម្រោងផ្នែកកាត់ដេរ

នៅដើមឆ្នាំ២០១៥ អង្គការកម្ពុជា-ហូឡង់បានចាប់ផ្តើមអនុវត្តគម្រោងបង្រៀនកាត់ដេរដល់ជនក្រីក្រនៅតាមទីជនបទក្នុងឃុំចំបី ស្រុកបាទី ខេត្តតាកែវ។ មានសិស្សចំនួន៦នាក់ដែលបានទទួលការបណ្តុះបណ្តាលពីអង្គការហើយតាមការវាយតម្លៃនៅចុងបញ្ចប់វគ្គរយៈពេលមួយឆ្នាំមានសិស្សចំនួន៣នាក់ដែលបានទទួលជោគជ័យយ៉ាងល្អ។

រីឯអ្នក៣នាក់ ត្រូវបានស្នើអោយបន្តវគ្គរយៈពេល៦ខែទៀត ដើម្បីបំពេញចំនុចខ្វះខាតរបស់ពួកគេ។

- មានសិស្សចំនួន៦នាក់ដែលបានទទួលការបណ្តុះបណ្តាលជំនាញកាត់ដេរ
- បានផ្តល់ជូនម៉ាស៊ីនកាត់ដេរដល់សិស្សចំនួន៦គ្រឿង
- សិស្សមករៀនត្រូវបានឧបត្ថមថវិកាសម្រាប់ម្ហូបអាហារប្រចាំថ្ងៃមួយពេល
- មានគ្រូបង្រៀនកាត់ដេរប្រចាំថ្ងៃនៅសាលាអង្គការ

## III- ថវិកាចំណាយប្រចាំឆ្នាំ budget 2016

ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៦ អង្គការកម្ពុជា-ហូឡង់បានទទួលថវិកាសរុបចំនួន **$ 76,369.48** ពីប្រភពជំនួយផ្សេងៗ ។ ចំណាយសរុប **$ 63902.56** និងថវិកានៅសល់ចុងឆ្នាំ ២០១៦ **$ 12466.92** ។

ហើយការចំណាយមានរាយដូចខាងក្រោម:

| ល.រ | ការពិពណ៌នា **Description** | ក្នុងផែនការ២០១៦ Budget plan 2016 | ចំណាយ២០១៦ Actual expended | ថវិកានៅសល់ចុងឆ្នាំ២០១៦ Ended balance 2016 |
|---|---|---|---|---|
| ១ | ចំណាយលើកម្មវិធីអប់រំ Education Program | $ 13,639.00 | $8,999.87 | $4,639.13 |
| ២ | ចំណាយលើកម្មវិធីគាំទ្រសង្គម Social Support program | $ 21,809.00 | $19,816.96 | $1,992.04 |
| ៣ | ចំណាយលើកម្មវិធីសុខភាព Health Care Program | $ 11,590.48 | $14,990.00 | -$ 3399.52 |
| ៤ | ចំណាយលើកម្មវិធីអនាម័យនិងទឹកស្អាត Water and Sanitation | $ 3,596.00 | $2,797.00 | $ 799.00 |
| ៥ | ចំណាយលើកម្មវិធីកាត់ដេរ Sewing program | $ 9,755.00 | $5,303.73 | $ 4,451.27 |
| ៦ | ចំណាយលើផ្នែករដ្ឋបាលនិងបុគ្គលិក Administration and staffs | $ 15,980.00 | $11,995.00 | $ 3,985 |
| | **ចំណាយសរុប Total** | **$ 76,369.48** | **$63902.56** | **$ 12466.92** |

សៀមរាប, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

អ្នកធ្វើរបាយការណ៍

សរ គឹមសិទ្ធ

អ្នកសម្របសម្រួលគម្រោង

សៀមរាប, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

បានឃើញ និង ឯកភាព

លោក ខាំយ៉ាន់

នាយកប្រតិបត្តិអង្គការកម្ពុជា-ហូឡង់